International
Labour
Organization







# ការណែនាំសង្ខេបស្តីពី អង្គការពលកម្មអន្តរជាតិ







“សន្តិភាព អាចមានជាសកល និងយូរអង្វែងបាន តែនៅពេលដែលសន្តិភាពនេះឈរលើមូលដ្ឋាន យុត្តិធម៌សង្គម តែប៉ុណ្ណោះ”

ធម្មនុញ្ញរបស់អង្គការពលកម្មអន្តរជាតិ ១៩១៩















# ការណែនាំសង្ខេបស្តីពីអង្គការពលកម្មអន្តរជាតិ

អង្គការពលកម្មអន្តរជាតិ (ILO) គឺជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលបូជាកាយចិត្តបង្កើនឱកាសអោយស្ត្រី និងបុរសទទួលបានការងារសមរម្យ និងប្រកបដោយផលិតភាពក្នុងល័ក្ខខ័ណ្ឌប្រកបដោយសេរីភាព សមធម៌ សន្តិសុខ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ គោលដៅចំបងរបស់អង្គការ គឺដើម្បីលើកកំពស់សិទ្ធិនៅកន្លែងការងារ លើកទឹកចិត្តអោយមានឱកាសការងារសមរម្យ បង្កើនកិច្ចការពារសង្គម និងពង្រឹងការសន្ទនាគ្នានៅក្នុងការដោះស្រាយបញ្ហាដែលទាក់ទងនឹងការងារ។

អង្គការពលកម្មអន្តរជាតិ គឺជាទីភ្នាក់ងារអង្គការសហប្រជាជាតិ "ត្រីភាគី" តែមួយគត់ ដោយសារតែអង្គការនេះប្រមូលផ្តុំតំណាងមកពីរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត ដើម្បីរួមគ្នាបង្កើតជាគោលនយោបាយ និងកម្មវិធីនានា។

អង្គការពលកម្មអន្តរជាតិ គឺជាស្ថាប័នសកល ដែលទទួលខុសត្រូវខាងការតាក់តែង និងត្រួតពិនិត្យបទដ្ឋានការងារអន្តរជាតិ។ ដោយបំពេញការងារជាមួយនឹងរដ្ឋជាសមាជិកចំនួន ១៨១ អង្គការពលកម្មអន្តរជាតិខិតខំព្យាយាមធានាថា បទដ្ឋានការងារត្រូវបានគោរពទាំងនៅក្នុងការអនុវត្តន៍ផង និងនៅក្នុងគោលការណ៍ផង។

# ពីអតីតកាល...



អង្គការពលកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩១៩ ក្នុងផ្នែកមួយនៃសន្ធិសញ្ញាវែរសៃ ដែលបានបញ្ចប់សង្គ្រាមលោកលើកទី ១ ដើម្បីឆ្លុះបញ្ចាំងអោយឃើញនូវជំនឿដែលថា សន្តិភាពជាសកល និងយូរអង្វែង អាចសំរេចទៅបាន តែនៅពេលដែលសន្តិភាពនេះឈរលើមូលដ្ឋានយុត្តិធម៌សង្គមតែប៉ុណ្ណោះ។ ស្ថាបនិករបស់អង្គការពលកម្មអន្តរជាតិ មានការប្តេជ្ញាចិត្តធ្វើការផ្សព្វផ្សាយល័ក្ខខ័ណ្ឌការងារមនុស្សធម៌ និងប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌ ទុក្ខលំបាកវេទនា និងភាពក្រីក្រ។ នៅក្នុងឆ្នាំ ១៩៤៤ នៅពេលដែលវិបត្តិអន្តរជាតិមួយទៀតកំពុងកើតមានឡើង សមាជិករបស់អង្គការពលកម្មអន្តរជាតិ បានបន្តប្រកាន់តាមគោលបំណងទាំងនេះ ដោយអនុម័តលើ *សេចក្តីប្រកាសហ្វីឡាដែលហ្វៀ* ដែលចែងថា ការងារមិនមែនជាផលិតផលដែលអាចទិញលក់នោះទេ ហើយកំណត់អំពីសិទ្ធិមនុស្ស និងសិទ្ធិខាងសេដ្ឋកិច្ចជាមូលដ្ឋាននៅក្រោមគោលការណ៍ថា "ភាពក្រីក្រនៅកន្លែងណាក៏ដោយ បង្កើតជាគ្រោះថ្នាក់ដល់វិបុលភាពនៅគ្រប់ទីកន្លែងទាំងអស់"។

នៅក្នុងឆ្នាំ ១៩៤៦ អង្គការពលកម្មអន្តរជាតិ បានក្លាយជាទីភ្នាក់ងារឯកទេសមុនគេបង្អស់ដែលបានចូលជាសមាជិក ឬដែលបានចូលរួមសម្ព័ន្ធជាមួយនឹងអង្គការសហប្រជាជាតិ ដែលទើបនឹងបង្កើតថ្មី។ នៅគំរប់ខួប ៥០ ឆ្នាំរបស់ខ្លួននៅក្នុងឆ្នាំ ១៩៦៩ អង្គការពលកម្មអន្តរជាតិបានទទួលពានរង្វាន់ណូបែលសន្តិភាព។

ការពង្រីកយ៉ាងសន្ធឹកសន្ធាប់នៃចំនួនប្រទេស ដែលជាសមាជិករបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងទសវត្សរ៍ក្រោយសង្គ្រាមលោកលើកទី ២ បានធ្វើអោយមានការផ្លាស់ប្តូរជាច្រើន។ អង្គការនេះ បានចាប់ផ្តើមអនុវត្តកម្មវិធីជំនួយបច្ចេកទេស ដើម្បីផ្តល់នូវជំនាញឯកទេស និងជំនួយដល់រដ្ឋាភិបាល កម្មករនិយោជិត និងនិយោជក នៅទូទាំងពិភពលោក ជាពិសេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងបណ្តាប្រទេសនានា ដូចជា ប៉ូឡូញ ឈីលី និងអាហ្វ្រិកខាងត្បូង ការគាំទ្រយ៉ាងខ្លាំងក្លារបស់អង្គការពលកម្មអន្តរជាតិខាងសិទ្ធិរបស់សហជីពបានជួយនៅក្នុងការតស៊ូអោយមានលទ្ធិប្រជាធិបតេយ្យ និងសេរីភាព។

# ...រហូតមកដល់ពេលបច្ចុប្បន្ន

កាលបរិច្ឆេទសំខាន់មួយទៀត សំរាប់អង្គការពលកម្មអន្តរជាតិ គឺឆ្នាំ ១៩៩៨ នៅពេលដែលគណៈប្រតិភូចូលរួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីវិស័យការងារ បានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីអំពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ។ គោលការណ៍ និងសិទ្ធិទាំងនេះគឺជាសិទ្ធិមានសេរីភាពបង្កើតជាសមាគម និងចរចាជាសមូហភាព ព្រមទាំងការលុបបំបាត់ពលកម្មកុមារ ការងារដោយបង្ខំ និងការរើសអើងដែលពាក់ព័ន្ធនឹងការងារ។ ការធានាអោយមានគោលការណ៍ និងសិទ្ធិជាមូលដ្ឋានទាំងនេះនៅកន្លែងការងារមានសារៈសំខាន់យ៉ាងខ្លាំង ព្រោះវាអនុញ្ញាតអោយប្រជាពលរដ្ឋ "ធ្វើការទាមទារដោយសេរី និងដោយឈរលើមូលដ្ឋាននៃឱកាសស្មើគ្នា នូវចំណែកដ៏សមរម្យរបស់ខ្លួនលើទ្រព្យសម្បត្តិ ដែលពួកគេបានជួយបង្កើតឱ្យមានឡើង និងដើម្បីសំរេចអោយបានពេញលេញនូវសក្តានុពលភាពរបស់ពួកគេក្នុងនាមជាមនុស្ស"។





# ការងារសមរម្យ...



ការងារ គឺជាស្នូលនៃសុខមាលភាពរបស់មនុស្ស។ បន្ថែមលើការផ្តល់ប្រាក់ចំណូល ការងារអាចត្រួសត្រាយផ្លូវអោយមានការរីកចំរើនផ្នែកសង្គម និងសេដ្ឋកិច្ចកាន់តែទូលំទូលាយ ក្នុងគោលដៅពង្រឹងមនុស្សម្នាក់ៗ គ្រួសារ និងសហគមន៍របស់ពួកគេ។ ប៉ុន្តែវឌ្ឍនភាពបែបនេះ អាស្រ័យលើការងារដែលមានភាពសមរម្យ។

ការងារសមរម្យ បណ្តុះបំណងប្រាថ្នារបស់មនុស្សនៅក្នុងជីវិតការងាររបស់ខ្លួន។ វារួមមាន ឱកាសទទួលបានការងារដែលប្រកបដោយផលិតភាព និងផ្តល់ប្រាក់ចំណូលសមរម្យ សន្តិសុខនៅកន្លែងការងារ និងការការពារខាងសង្គមកិច្ចសំរាប់ក្រុមគ្រួសារ។ ការងារសមរម្យ មានន័យថាជាក្តីសង្ឃឹមកាន់តែប្រសើរសំរាប់ការអភិវឌ្ឍន៍ខ្លួនឯង និងសមាហរណកម្មសង្គម ព្រមទាំងសេរីភាពសំរាប់មនុស្ស ដើម្បីបង្ហាញពីក្តីកង្វល់របស់ខ្លួន រៀបចំ និងចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ខ្លួន។ ដើម្បីសំរេចគោលដៅនេះ ចាំបាច់ត្រូវមានឱកាស និងការប្រព្រឹត្តស្មើភាពគ្នាចំពោះគ្រប់ស្ត្រី និងបុរសទាំងអស់។

ការងារសមរម្យ គឺជាគន្លឹះនៃការលុបបំបាត់ភាពក្រីក្រ។ ប្រសិនបើស្ត្រី និងបុរស ទទួលបានការងារសមរម្យ ពួកគេអាចទទួលបានចំណែកនៃអត្ថប្រយោជន៍ដែលកើតឡើង ដោយសារកំណើនសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ។ ការពង្រីកឱកាសទទួលបានការងារសមរម្យអោយដល់មនុស្សកាន់តែច្រើននាក់បន្ថែមទៀត គឺជាធាតុមួយយ៉ាងសំខាន់ក្នុងការធ្វើអោយសកលភាវូបនិយកម្មកាន់មានការចូលរួម និងកាន់តែយុត្តធម៌។ ដូច្នេះការបង្កើតការងារសមរម្យ ត្រូវតែជាស្នូលនៃគោលនយោបាយអភិវឌ្ឍន៍។

# ... នៅក្នុងពិភពសកលភាវូបនិយកម្ម

នៅក្នុងឆ្នាំ ២០០៤ តួនាទីរបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងការលើកកំពស់យុទ្ធសាស្ត្រអោយមានសកលភាវូបនិយកម្មមួយ ដែលមានភាពយុត្តិធមិ ត្រូវបានគាំទ្រដោយរបាយការណ៍នៃគណៈកម្មការពិភពលោកខាងទិដ្ឋភាពសង្គមនៃសកលភាវូបនិយកម្ម។

កំលាំងចលករ ដើម្បីលើកស្ទួយការងារសមរម្យ គឺបានបន្តអត្តិភាពអង្គការពលកម្មអន្តរជាតិ ដោយរួមបញ្ចូលគ្នានូវអ្វី ដែលអង្គការនេះធ្វើនៅកំរិតអន្តរជាតិ កំរិតតំបន់ កំរិតជាតិ និងកំរិតមូលដ្ឋាន។ នៅក្នុងការនាំរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត អោយធ្វើការរួមគ្នាដើម្បីបង្កើតបទដ្ឋានការងារ ត្រួតពិនិត្យការអនុវត្តន៏បទដ្ឋានទាំងនេះ លើកកំពស់ការយល់ដឹង បង្កើតគោលនយោបាយ និងផ្តួចផ្តើមកម្មវិធីនានា អង្គការពលកម្មអន្តរជាតិមានគោលបំណងធានាថា កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនមានឫសគល់ចេញពីសេចក្តីត្រូវការរបស់ស្ត្រី និងបុរសដែលធ្វើការងារ។

អង្គការពលកម្មអន្តរជាតិ បំពេញការងារយ៉ាងសកម្មជាមួយនឹងអង្គការសហប្រជាជាតិ និងទីភ្នាក់ងារពហុភាគីដទៃទៀត ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធីនានា ដែលគាំទ្រដល់ការបង្កើតឱកាសការងារសមរម្យ អោយក្លាយទៅជាចំនុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រ។





# កិច្ចសន្ទនាសង្គម

អ្វីដែលជាមូលដ្ឋាននៃការងាររបស់អង្គការពលកម្មអន្តរជាតិ គឺសារៈសំខាន់នៃសហប្រតិបត្តិការ រវាងរដ្ឋាភិបាល និងអង្គការរបស់និយោជក និងអង្គការរបស់កម្មករនិយោជិតនៅក្នុងការជំរុញ អោយមានវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ច។ កិច្ចសន្ទនាគ្នារវាងរដ្ឋាភិបាល និង "ដៃគូសង្គម" ទាំងពីរនេះ លើកកំពស់អោយមានការឯកភាពគ្នាជាឯកច្ឆ័ន្ទ និងការចូលរួមជាលក្ខណៈ ប្រជាធិបតេយ្យពីសំណាក់អ្នកដែលមានតួនាទីសំខាន់នៅក្នុងពិភពការងារ។

"កិច្ចសន្ទនាសង្គម" នេះអាចមានន័យថា ជាការចរចា ការពិគ្រោះយោបល់ ឬគ្រាន់តែត្រឹមជាការ ផ្លាស់ប្តូរមតិយោបល់គ្នា រវាងតំណាងរបស់និយោជក កម្មករនិយោជិត និងរដ្ឋាភិបាល។ វាអាច រួមមាន ទំនាក់ទំនងរវាងកម្មករនិយោជិត ជាមួយនឹងអ្នកគ្រប់គ្រង ដោយមាន ឬដោយពុំមានការ ពាក់ព័ន្ធដោយផ្ទាល់របស់រដ្ឋាភិបាល។ កិច្ចសន្ទនាសង្គម គឺជាឧបករណ៍មួយ ដែលមានភាពបត់បែន ដែលផ្តល់លទ្ធភាពអោយរដ្ឋាភិបាល និងអង្គការរបស់និយោជក និងអង្គការរបស់កម្មករនិយោជិត អាចគ្រប់គ្រងការផ្លាស់ប្តូរ និងសំរេចគោលបំណងផ្នែកសេដ្ឋកិច្ច និងសង្គម។

រចនាសម្ព័ន្ធដំបូងបង្អស់របស់អង្គការពលកម្មអន្តរជាតិ ដែលកម្មករនិយោជិត និងនិយោជករួមគ្នា មានសំលេងស្មើគ្នានឹងរដ្ឋាភិបាលនៅក្នុងការងារនៃក្រុមប្រឹក្សាអភិបាលរបស់ខ្លួន បង្ហាញពី សកម្មភាពជាក់ស្តែងនៃកិច្ចសន្ទនាសង្គម។ វាធានាថា ទស្សនៈ ឬការយល់ឃើញរបស់ដៃគូសង្គម ត្រូវបានឆ្លុះបញ្ចាំងយ៉ាងជិតស្និទ្ធនៅក្នុងបទដ្ឋានការងារ គោលនយោបាយ និងកម្មវិធីរបស់អង្គការ ពលកម្មអន្តរជាតិ។



**កិច្ចសន្ទនាសង្គម** គឺជាឧបករណ៍មួយ ដែលមានភាពបត់បែន ដើម្បីសំរេចនូវ**ការផ្លាស់ប្តូរ**ផ្នែកសេដ្ឋកិច្ច និងសង្គម

ក្នុងពេលជាមួយគ្នានេះ អង្គការពលកម្មអន្តរជាតិជួយដល់រដ្ឋាភិបាល អង្គការនិយោជកនិងអង្គការរបស់កម្មករនិយោជិត បង្កើតនូវទំនាក់ទំនងការងារល្អ សំរួលច្បាប់ការងារទៅតាមការផ្លាស់ប្តូរនៃកាលៈទេសៈសេដ្ឋកិច្ច និងសង្គម និងកែលំអរដ្ឋបាលការងារ ។ នៅក្នុងការគាំទ្រ និងការពង្រឹងដល់អង្គការរបស់និយោជក និងអង្គការរបស់កម្មករនិយោជិត អង្គការពលកម្មអន្តរជាតិជួយបង្កើតអោយមានល័ក្ខខ័ណ្ឌសំរាប់កិច្ចសន្ទនាដ៏មានប្រសិទ្ធភាពជាមួយនឹងរដ្ឋាភិបាល និងរវាងគ្នាទៅវិញទៅមក ។

## អភិបាលកិច្ច និងការតាក់តែងគោលនយោបាយ

គោលនយោបាយទូលំទូលាយរបស់អង្គការពលកម្មអន្តរជាតិ ត្រូវបានដាក់ចេញដោយសន្និសីទអន្តរជាតិស្តីពីវិស័យការងារ ដែលប្រជុំម្តងក្នុងមួយឆ្នាំ និងជាវេទិកាជួបជុំគ្នានៃតំណាងសមាជិករបស់អង្គការនេះ ។ សន្និសីទនេះ ក៏អនុម័តផងដែរ លើបទដ្ឋានការងារថ្មីៗ និងផ្តល់ការឯកភាពលើផែនការការងារ និងថវិការបស់អង្គការពលកម្មអន្តរជាតិ ។

នៅរវាងចន្លោះសន្និសីទទាំងនេះ អង្គការពលកម្មអន្តរជាតិ ត្រូវបានតំរង់ទិសដោយក្រុមប្រឹក្សាភិបាលរបស់ខ្លួន ដែលរួមមានសមាជិកជារដ្ឋាភិបាលចំនួន ២៨ សមាជិកជានិយោជកចំនួន ១៤ និងសមាជិកជាកម្មករនិយោជិតចំនួន ១៤ ។ ការិយាល័យពលកម្មអន្តរជាតិ ដែលជាលេខាធិការដ្ឋានរបស់អង្គការពលកម្មអន្តរជាតិមានទីស្នាក់ការរបស់ខ្លួននៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ហើយមានការិយាល័យមូលដ្ឋាននៅក្នុងប្រទេសជាង ៤0 ។

នៅក្នុងឆ្នាំ ១៩៩៩ លោក Juan Somavia មកពីប្រទេសឈីលី បានក្លាយជាអគ្គនាយកទី ៩ របស់អង្គការពលកម្មអន្តរជាតិ ។ លោក គឺជាមនុស្សទីមួយមកពីអឌ្ឍគោលខាងត្បូង ដែលធ្វើជាអ្នកដឹកនាំរបស់អង្គការនេះ ។



# បទដ្ឋាន

ចាប់តាំងពីដើមដំបូងមកម្លេះ អង្គការពលកម្មអន្តរជាតិបានព្យាយាមកំណត់ និងធានាសិទ្ធិការងារ និងកែលំអល័ក្ខខ័ណ្ឌរបស់មនុស្សដែលធ្វើការងារ តាមរយៈការបង្កើតអោយមានជាប្រព័ន្ធបទដ្ឋានការងារអន្តរជាតិមួយ ដែលស្តែងឡើងក្នុងទំរង់ជាអនុសញ្ញា អនុសាសន៏ និងក្រមប្រតិបត្តិ ។

ចាប់តាំងពីពេលនោះមក អង្គការពលកម្មអន្តរជាតិបានអនុម័តលើអនុសញ្ញាចំនួនជាង ១៨០ និងអនុសាសន៏ចំនួនជាង ១៩០ ដែលគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃពិភពការងារ ។ ថ្មីៗនេះ អង្គភាពច្បាប់ការងារអន្តរជាតិនេះ ត្រូវបានពិនិត្យឡើងវិញដោយក្រុមប្រឹក្សាភិបាល ដែលបានសំរេចថា អនុសញ្ញាជាង ៧០ ដែលត្រូវបានអនុម័តនៅមុនឆ្នាំ ១៩៨៥ នៅតែមានបច្ចុប្បន្នភាពពេញលេញ ហើយអនុសញ្ញាដែលនៅសល់ត្រូវមានការពិនិត្យឡើងវិញ ឬដកចេញតែម្តង ។ លើសពីនេះទៅទៀត ក្រមប្រតិបត្តិជាច្រើនត្រូវបានបង្កើតឡើង ។ នៅក្នុងផ្នែកផ្សេងៗ ដូចជាការឈប់សំរាកលំហែមាតុភាព និងការការពារជនចំណាកស្រុកជាដើម បទដ្ឋានទាំងនេះដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតច្បាប់ជាតិ ។ ដំណើរការត្រួតពិនិត្យជួយធានាថា បទដ្ឋានដែលត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិកនីមួយៗ ត្រូវបានយកទៅអនុវត្ត ហើយអង្គការពលកម្មអន្តរជាតិផ្តល់យោបល់ណែនាំនៅក្នុងការធ្វើពង្រាងច្បាប់ជាតិស្តីពីការងារ ។

ដោយមានការអនុម័តលើ*សេចក្តីថ្លែងការណ៏ស្តីអំពីគោលការណ៏ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ* នៅក្នុងឆ្នាំ ១៩៩៨ រដ្ឋដែលជាសមាជិករបស់អង្គការពលកម្មអន្តរជាតិបានសំរេចចិត្តជាផ្លូវការអនុវត្តតាមបទដ្ឋានការងារសំខាន់ៗ ដោយមិនគិតថាខ្លួនបានផ្តល់សច្ចាប័នលើអនុសញ្ញាដែលពាក់ព័ន្ធនោះឡើយ ។ ទាំងនេះ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងស្នូលគ្រឹះនៃការងារសមរម្យ ។




## បទដ្ឋាន**ការងារសំខាន់ៗ** គឺជាស្នូលគ្រឹះនៃ **ការងារសមរម្យ**

# សេរីភាពនៃការបង្កើតសមាគម

## សេរីភាពនៃការបង្កើតសមាគម គឺជាមូលដ្ឋានគ្រឹះសំរាប់**វឌ្ឍនភាពសង្គម និងសេដ្ឋកិច្ច**



សិទ្ធិរបស់កម្មករនិយោជិត និងនិយោជក ក្នុងការបង្កើត និងចូលរួមនៅក្នុងអង្គការនានាតាមការជ្រើសរើសរបស់ខ្លួន គឺជាផ្នែកមួយយ៉ាងសំខាន់របស់សង្គមមួយដែលមានសេរីភាព និងបើកចំហ។ វា គឺជាសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលដើរតួនាទីជាគ្រឹះសំរាប់វឌ្ឍនភាពសង្គម និងសេដ្ឋកិច្ច។ ភ្ជាប់គ្នាជាមួយនេះ គឺជាការទទួលស្គាល់យ៉ាងមានប្រសិទ្ធភាពលើសិទ្ធិចរចាជាសមូហភាព។ សំលេង និងភាពជាតំណាង គឺជាផ្នែកមួយយ៉ាងសំខាន់នៃការងារសមរម្យ។

វត្តមាននៃអង្គការឯករាជ្យ សំរាប់កម្មករនិយោជិត និងនិយោជក ដើរតួជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធត្រីភាគីរបស់អង្គការពលកម្មអន្តរជាតិ ហើយការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាព និងគោលនយោបាយរបស់អង្គការពលកម្មអន្តរជាតិ ពង្រឹងបន្ថែមដោយផ្ទាល់ និងដោយប្រយោលលើសេរីភាពនៃការបង្កើតសមាគម។ ចាប់តាំងពីការផ្តល់យោបល់ដល់រដ្ឋាភិបាល ស្តីពីច្បាប់ការងារ រហូតដល់ការផ្តល់ការអប់រំ និងការបណ្តុះបណ្តាលសំរាប់សហជីព និងក្រុមនិយោជក អង្គការពលកម្មអន្តរជាតិ តែងតែចូលរួមជាទៀងទាត់នៅក្នុងការលើកកំពស់សេរីភាពនៃការបង្កើតសមាគម។

គណៈកម្មាធិការខាងសេរីភាពនៃការបង្កើតសមាគមរបស់អង្គការពលកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៥១ ដើម្បីត្រួតពិនិត្យលើការរំលោភបំពានលើសិទ្ធិរៀបចំជាសមាគមរបស់កម្មករនិយោជិត និងរបស់និយោជក។ គណៈកម្មាធិការនេះ បានត្រួតពិនិត្យលើរឿងក្តីជាង ២ ០០០ ករណី ដែលរួមមានការចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើឃាត ការបាត់ខ្លួន ការវាយដំលើរូបរាងកាយ ការចាប់ខ្លួន និងការបង្ខំនិរទេសខ្លួនរបស់មន្ត្រីសហជីព។ គណៈកម្មាធិការនេះ គឺជាគណៈកម្មាធិការត្រីភាគី ហើយដោះស្រាយបណ្តឹងចរចានានានៅក្នុងរដ្ឋដែលជាសមាជិករបស់អង្គការពលកម្មអន្តរជាតិ មិនថារដ្ឋទាំងនេះបានផ្តល់សច្ចាប័នលើអនុសញ្ញានានាដែលពាក់ព័ន្ធនឹងសេរីភាពនៃការបង្កើតសមាគម ហើយឬនៅនោះទេ។

តាមរយៈគណៈកម្មាធិការខាងសេរីភាពនៃការបង្កើតសមាគមនេះ និងតាមរយៈយន្តការត្រួតពិនិត្យដទៃទៀត អង្គការពលកម្មអន្តរជាតិបានការពារសិទ្ធិរបស់សហជីព និងសិទ្ធិរបស់អង្គការនិយោជកជាញឹកញាប់។ នៅក្នុងករណីជាច្រើន អង្គការទាំងនេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្លាស់ប្តូរទៅរកលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ខ្លួន។

# ការងារដោយបង្ខំ

បើតាមការប៉ាន់ស្មាន យ៉ាងហោចណាស់មានមនុស្សចំនួន ១២ លាននាក់ នៅទូទាំងពិភពលោក គឺជាជនរងគ្រោះដោយសារការងារដោយបង្ខំ ដែលក្នុងនោះ ១០ លាន់នាក់ ត្រូវបានគេកេងប្រវ័ញ្ច តាមរយៈការងាដោយបង្ខំនៅក្នុងសេដ្ឋកិច្ចឯកជន ជាជាងរងការកេងប្រវ័ញ្ចដោយផ្ទាល់ពីរដ្ឋ ។ អង្គការពលកម្មអន្តរជាតិបានប៉ាន់ប្រមាណថា ចំណូលប្រចាំឆ្នាំចំនួន ៣២ ពាន់ លានដុល្លាសហរដ្ឋអាមេរិក ត្រូវបានបង្កើតឡើងដោយការងារដោយបង្ខំលើមនុស្សដែលត្រូវបានគេជួញដូរ ។

ការងារដោយបង្ខំ មានទំរង់ផ្សេងៗគ្នាដូចជា ការជាប់បំណុល ការជួញដូរ និងទំរង់ដទៃទៀតនៃទាសភាពបែបទំនើប ។ ជនរងគ្រោះដែលងាយរងគ្រោះជាងគេ គឺស្ត្រី និងកុមារី ដែលត្រូវបានគេបង្ខំអោយបំរើក្នុងពេស្យាចារ ជនចំណាកស្រុកដែលជាប់អន្ទាក់បំណុល និងកន្លែងធ្វើការដែលមានល័ក្ខខ័ណ្ឌការងារមិនល្អ ឬអ្នកធ្វើការក្នុងកសិដ្ឋានដែលត្រូវបានគេឃុំទុកដោយល្បិចមិនស្របច្បាប់ និងទទួលបានកំរៃតិចតួច ឬមិនបានទទួលកំរៃទាល់តែសោះ ។

ចាប់តាំងពីកំណើតរបស់ខ្លួនមក អង្គការពលកម្មអន្តរជាតិបានធ្វើការងារ ដើម្បីដោះស្រាយបញ្ហាការងារដោយបង្ខំ និងល័ក្ខខ័ណ្ឌនានា ដែលធ្វើអោយបញ្ហានេះកាន់តែកើនឡើង និងបានបង្កើតអោយមានកម្មវិធីសកម្មភាពពិសេសខាងការងារដោយបង្ខំ ក្នុងបុព្វហេតុពង្រឹងបន្ថែមលើកិច្ចខិតខំប្រឹងប្រែងនេះ ។ ក្នុងភាពជាដៃគូជាមួយនឹងកម្មករនិយោជិត និយោជក សង្គមស៊ីវិល និងអង្គការអន្តរជាតិដទៃទៀត អង្គការពលកម្មអន្តរជាតិខិតខំដោះស្រាយគ្រប់ទិដ្ឋភាពទាំងអស់នៃការងារដោយបង្ខំដែលមានតាំងពីវិធានការបង្ការដូចជា គំរោងកែលំអជីវភាពរស់នៅក្នុងសហគមន៏ ដែលជាដើមកំណើតរបស់ជនរងគ្រោះដោយសារការជួញដូរ រហូតដល់ការគាំទ្រដល់កម្មករនិយោជិត ដែលត្រូវបានគេលែងអោយមានសេរីភាព ។ កម្មវិធីនានាអាចរួមមាន មីក្រូហិរញ្ញវត្ថុ ឱកាសបណ្តុះបណ្តាល និងការសំរបសំរួលអោយទទួលបានការអប់រំ ។

អង្គការពលកម្មអន្តរជាតិ ក៏កំពុងជំរុញអោយមានច្បាប់ជាតិដែលមានប្រសិទ្ធភាព និងយន្តការពង្រឹងការអនុវត្តន៏ច្បាប់ ដែលខ្លាំងក្លាជាងមុនផងដែរដូចជា ទណ្ឌកម្មតាមផ្លូវច្បាប់ និងការដាក់ទោសលើអ្នកដែលកេងប្រវ័ញ្ចពលករដែលត្រូវបានគេបង្ខំ ។ តាមរយៈការលើកកំពស់ការយល់ដឹង អង្គការពលកម្មអន្តរជាតិព្យាយាមបញ្ជាំងអោយឃើញពីការរំលោភបំពានសិទ្ធិមនុស្ស និងសិទ្ធិការងារបែបនេះ ។



អង្គការពលកម្មអន្តរជាតិ ខិតខំ **ដោះស្រាយ** គ្រប់ទិដ្ឋភាពទាំងអស់នៃ ការងារដោយបង្ខំ

# ពលកម្មកុមារ

## ពលកម្មកុមារ កំពុងមាន ការធ្លាក់ចុះជាសកល

មានកុមារជាង ២00 លាននាក់ កំពុងធ្វើការនៅទូទាំងពិភពលោក ហើយពួកគេជាច្រើននាក់ធ្វើការងារពេញម៉ោង។ ពួកគេមិនទទួលការអប់រំអោយបានគ្រប់គ្រាន់ សុខភាពល្អ និងសេរីភាពជាមូលដ្ឋានឡើយ។ ក្នុងចំណោមកុមារទាំងនេះ កុមារចំនួន ១២៦ លាននាក់ (ឬម្នាក់ក្នុងចំណោមកុមារ ១២ នាក់ នៅទូទាំងពិភពលោក) កំពុងទទួលរងនូវទំរង់គ្រោះថ្នាក់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដែលជាការងារធ្វើអោយមានគ្រោះថ្នាក់ដល់សុខមាលភាពខាងរូបរាងកាយ បញ្ញា ឬសីលធម៌របស់ពួកគេ។

ជាង ១៥ ឆ្នាំកន្លងទៅនេះ ពិភពលោកចាប់ផ្តើមដឹងថា ពលកម្មកុមារ គឺជាបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាសិទ្ធិមនុស្សបន្ទាន់មួយ។ នាពេលបច្ចុប្បន្ននេះ ពលកម្មកុមារជាសកលកំពុងមានការថយចុះ ហើយប្រសិនបើនិន្នាការនេះនៅតែបន្តទៅមុខទៀត ទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារអាចត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងទសវត្សរ៍ខាងមុខនេះ។ នេះ គឺជាលទ្ធផលដោយផ្ទាល់មួយនៃចលនាអន្តរជាតិដ៏មានឥទ្ធិពល ដើម្បីលុបបំបាត់ពលកម្មកុមារ។

ចលនានេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ទុះដ៏លឿនដែលមិនធ្លាប់មានពីមុនមក ដោយប្រទេសនានាកំពុងផ្តល់សច្ចាប័នដល់អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ដោយអនុម័តនៅក្នុងឆ្នាំ ១៩៩៩ អនុសញ្ញានេះ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិកចំនួន ៩ ក្នុងចំណោម ១០ នៃរដ្ឋជាសមាជិកចំនួនទាំង ១៨១ របស់អង្គការពលកម្មអន្តរជាតិ។ ស្រដៀងគ្នានេះផងដែរ អនុសញ្ញាស្តីពីអាយុអប្បបរមារបស់អង្គការពលកម្មអន្តរជាតិ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៧៣ ឥឡូវនេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិកចំនួន ៤ ក្នុងចំណោមរាល់រដ្ឋជាសមាជិករបស់អង្គការពលកម្មអន្តរជាតិចំនួន ៥។



អង្គការពលកម្មអន្តរជាតិ គឺជាម៉ាស៊ីនសំខាន់បំផុតនៅពីក្រោយចលនា ដែលមានការរីកចំរើននេះ។ កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៩២ ឥឡូវនេះមានសកម្មភាពនៅក្នុងប្រទេសជាង ៨0។ ដូចគ្នានឹងទិដ្ឋភាពដទៃទៀតនៃការងារសមរម្យផងដែរ ការលុបបំបាត់ពលកម្មកុមារ គឺជាបញ្ហានៃការអភិវឌ្ឍន៍ផង និងបញ្ហាសិទ្ធិមនុស្សផង។ គោលនយោបាយ និងកម្មវិធីរបស់អង្គការពលកម្មអន្តរជាតិ មានគោលបំណងជួយធានាថា កុមារទទួលបានការអប់រំ និងការបណ្តុះបណ្តាល ដែលពួកគេត្រូវការ ដើម្បីក្លាយជាមនុស្សពេញវ័យដែលប្រកបដោយផលិតភាពនៅក្នុងការងារសមរម្យ។

# ការរើសអើង

មនុស្សរាប់រយលាននាក់ រងគ្រោះដោយសារការរើសអើងនៅក្នុងពិភពការងារ ។ នេះមិនត្រឹមតែរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋានបំផុតនោះទេ ថែមទាំងមានផលវិបាកផ្នែកសង្គម និងសេដ្ឋកិច្ចកាន់តែធំផងដែរ ។ ការរើសអើង បង្អាក់ឱកាសមិនអោយកើតមានឡើង ខ្ជះខ្ជាយទេពកោសល្យរបស់មនុស្សដែលចាំបាច់សំរាប់ការរីកចំរើនសេដ្ឋកិច្ច និងធ្វើអោយកាន់តែលេចចេញយ៉ាងច្បាស់នូវភាពតានតឹង និងវិសមភាពនៅក្នុងសង្គម ។ ការប្រយុទ្ធប្រឆាំងនឹងការរើសអើង គឺជាផ្នែកមួយយ៉ាងសំខាន់នៃការលើកកំពស់ការងារសមរម្យ ហើយជោគជ័យនៃការងារជួរមុខនេះមានលើសពីនៅកន្លែងធ្វើការទៅទៀត ។

បញ្ហានានាដែលមានទំនាក់ទំនងជាមួយនឹងការរើសអើង មានវត្តមាននៅទូទាំងរង្វង់ការងាររបស់អង្គការពលកម្មអន្តរជាតិ ។ ឧទាហរណ៍ តាមរយៈការលើកកំពស់សេរីភាពនៃការបង្កើតសមាគម អង្គការពលកម្មអន្តរជាតិព្យាយាមបង្ការមិនអោយមានការរើសអើងប្រឆាំងនឹងសមាជិក និងមន្ត្រីរបស់សហជីព ។

កម្មវិធីប្រយុទ្ធប្រឆាំងនឹងការងារដោយបង្ខំ និងពលកម្មកុមារ រួមមានការជួយដល់កុមារី និងស្ត្រីដែលជាប់អន្ទាក់ក្នុងពេស្យាចារ ឬការបង្ខំអោយធ្វើការងារបំរើតាមផ្ទះ ។ ការមិនរើសអើង គឺជាគោលការណ៍ចំបងមួយនៅក្នុងក្រមប្រតិបត្តិរបស់អង្គការពលកម្មអន្តរជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ និងស្តីពីពិភពការងារ ។ គោលការណ៍ណែនាំរបស់អង្គការពលកម្មអន្តរជាតិ ស្តីពីច្បាប់ការងារ មានដាក់បញ្ចូលបញ្ញត្តិស្តីពីការរើសអើង ។

នៅក្នុងពេលជាមួយគ្នានេះផងដែរ សមភាពយេនឌ័រ ត្រូវបានដាក់បញ្ចូលនៅក្នុងគ្រប់សកម្មភាពទាំងអស់របស់អង្គការពលកម្មអន្តរជាតិ ។ នេះឆ្លុះបញ្ចាំងពីបញ្ហាផ្សេងៗ ដែលបន្តកើតមានឡើងដែលប្រឈមដោយស្ត្រីនៅក្នុងទីផ្សារការងារ ។ ស្ត្រីនៅតែបន្តទទួលបានចំណូលតិចជាងបុរសដែលភាគច្រើនស្ត្រីប្រកបមុខរបរដែលមានប្រាក់ឈ្នួលតិច និងមិនសូវមានការការពារ ហើយគឺជាអ្នកធ្វើការនៅក្នុងស្ថានភាពក្រៅប្រព័ន្ធខុសពីធម្មតា និងមិនទទួលបានប្រាក់ឈ្នួល ។ អង្គការពលកម្មអន្តរជាតិធ្វើការងារ ដើម្បីពង្រីកឱកាសការងារសំរាប់ស្ត្រី កែលំអល័ក្ខខ័ណ្ឌការងារ និងលុបបំបាត់ការរើសអើងផ្នែកយេនឌ័រ ។ អង្គការពលកម្មអន្តរជាតិលើកទឹកចិត្តដល់សហគ្រិនភាពរបស់ស្ត្រីតាមរយៈសេវាគាំទ្រនានា ការបង្កើតអាជីវកម្ម ការបណ្តុះបណ្តាល មីក្រូហិរញ្ញវត្ថុ និងការចងក្រងឯកសារអំពីការអនុវត្តន៍ល្អៗ ហើយជួយអង្គការរបស់កម្មករនិយោជិតក្នុងការការពារ និងពង្រីកសិទ្ធិរបស់ស្ត្រីនៅកន្លែងការងារ និងលើកកំពស់តួនាទីរបស់ពួកគេនៅក្នុងសហជីព និងសង្គមជាទូទៅ ។



ការរើសអើងបង្អាក់ឱកាសមិនអោយកើតមានឡើង ខ្ជះខ្ជាយ**ទេពកោសល្យ**របស់មនុស្សដែលចាំបាច់សំរាប់**ការរីកចំរើន**សេដ្ឋកិច្ច

# ការងារ និងចំណូល

## ការដាក់**វិស័យការងារជាចំនុចស្នូល**នៃគោលនយោបាយសេដ្ឋកិច្ច និងសង្គម គឺជាសេចក្តីត្រូវការយ៉ាងធំផុត

ជាមួយនឹងភាពគ្មានការងារធ្វើជាសកលក្នុងកំរិតខ្ពស់ជាប្រវត្តិសាស្ត្រ ការដាក់វិស័យការងារជាចំនុចស្នូលនៃគោលនយោបាយសេដ្ឋកិច្ច និងសង្គម គឺជាសេចក្តីត្រូវការយ៉ាងធំផុត។ សូម្បីតែនៅក្នុងចំណោមអ្នកដែលធ្វើការងារ វិសាលភាពនៃភាពក្រីក្រ គូសបញ្ជាក់ពីសេចក្តីត្រូវការអោយមានចំនួនការងារប្រកបដោយផលិតភាព និងភាពសមរម្យកាន់តែច្រើនជាងមុនបន្ថែមទៀត។

ល្បឿនមិនគ្រប់គ្រាន់នៅក្នុងការបង្កើតការងារសមរម្យនៅទូទាំងពិភពលោក ទាមទារអោយមានការសហការគ្នាជាអន្តរជាតិបន្ថែមទៀត ខាងផ្នែកគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយទីផ្សារការងារសកម្មនៅកំរិតជាតិ។

ការងារប្រកបដោយផលិតភាព និងដែលអាចជ្រើសរើសបានដោយសេរី គឺជាស្នូលនៃតួនាទីភារកិច្ចរបស់អង្គការពលកម្មអន្តរជាតិ ហើយអង្គការនេះមានការប្តេជ្ញាចិត្តចំពោះការងារពេញលេញ។ អង្គការពលកម្មអន្តរជាតិកំណត់គោលនយោបាយ ដែលជួយបង្កើត និងរក្សាការងារសមរម្យ និងចំណូល (ជាគោលនយោបាយ ដែលត្រូវបានបង្កើតឡើងនៅក្នុងរបៀបវារៈការងារសកលគ្រប់ជ្រុងជ្រោយ ដែលដាក់ចេញដោយសមាជិកទាំង ៣ ភាគីរបស់អង្គការពលកម្មអន្តរជាតិ)។ អង្គការនេះ ធ្វើការស្រាវជ្រាវ និងចូលរួមនៅក្នុងការពិភាក្សាជាអន្តរជាតិអំពីយុទ្ធសាស្ត្រវិស័យការងារ។



អង្គការពលកម្មអន្តរជាតិ មានការព្រួយបារម្ភជាពិសេស អំពីភាពគ្មានការងារធ្វើយ៉ាងច្រើនរបស់យុវជន និងយុវតី (ស្មើរតែពាក់កណ្តាលនៃអ្នកដែលគ្មានការងារធ្វើនៅក្នុងពិភពលោក គឺជាយុវជន) ហើយអង្គការនេះខិតខំជួយពួកគេ និងរដ្ឋាភិបាលរបស់ពួកគេ តាមរយៈការផ្តល់យោបល់លើគោលនយោបាយ និងគំនិតផ្តួចផ្តើមជាក់ស្តែងអំពីការបណ្តុះបណ្តាល និងវិស័យការងារ ។

អង្គការពលកម្មអន្តរជាតិ បាននាំមុខគេលើការវិភាគ និងសកម្មភាព ដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ វាក្យស័ព្ទនេះ ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីការងារដែលបានធ្វើនៅក្រៅដែនគ្របដណ្តប់របស់ច្បាប់ផ្លូវការ និងយន្តការអនុវត្តន៏នានា។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៏នានា ជាងពាក់កណ្តាលនៃកំលាំងពលកម្មដែលធ្វើការងារ នៅក្នុងវិស័យមិនមែនកសិកម្ម គឺស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ស្ត្រីភាគច្រើននៅក្នុងប្រទេសទាំងនេះ ធ្វើការងារជាលក្ខណៈក្រៅប្រព័ន្ធ ដែលជារឿយៗជាអ្នកលក់ដូរតាមដងផ្លូវ ។ ការងារក្រៅប្រព័ន្ធ ភាគច្រើនមិនប្រកបដោយផលិតភាព មិនជាប់លាប់ ទទួលបានចំណូលតិច ហើយធ្វើឡើងនៅក្រោមល័ក្ខខ័ណ្ឌមិនល្អ ។ ការជួយអោយនិយោជក និងកម្មករនិយោជិត អោយរួចផុតពីភាពក្រៅប្រព័ន្ធ ទាមទារអោយមានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដើម្បីបង្កើនជំនាញ និងផលិតភាព កែលំអច្បាប់ និងការអនុវត្តន៏ច្បាប់ និងលើកស្ទួយដល់ស្ថាប័នដែលទ្រទ្រង់ដោយខ្លួនឯង ។

ការចេញផ្សាយជាទៀងទាត់នូវរបាយការណ៏ចំនួន ២ របស់អង្គការពលកម្មអន្តរជាតិ ដោយរួមមាន សូចនាករសំខាន់ៗនៃទីផ្សារការងារ ធ្វើការវិភាគលើនិន្នាការ និងផ្តល់នូវទិន្នន័យស្ថិតិយ៉ាងទូលំទូលាយ ។

អង្គការពលកម្មអន្តរជាតិ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងយោបល់ណែនាំនៅក្នុងវិស័យនានាចាប់តាំងពីការបណ្តុះបណ្តាល និងជំនាញ រហូតដល់មីក្រូហិរញ្ញវត្ថុ និងការបង្កើតអាជីវកម្មខ្នាតតូច ។

អង្គការនេះបានផ្តល់យោបល់ណែនាំដល់ប្រទេសនានា ដែលកំពុងផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការមជ្ឈិម ទៅជាសេដ្ឋកិច្ចទីផ្សារស្តីពីគោលនយោបាយការងារ ទីផ្សារការងារ និងធនធានមនុស្ស ។ អង្គការនេះ ក៏ធ្វើការងារដើម្បីលើកកំពស់ការវិនិយោគដែលផ្តល់អោយមានការងារច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ។



# ប្រាក់ឈ្នួល និងលក្ខខណ្ឌការងារដទៃទៀត

ខណៈពេលដែលប្រាក់ឈ្នួលអាចមានការកើនឡើង នៅក្នុងប្រទេសជាច្រើន ប្រាក់ឈ្នួលជារឿយៗ នៅតែមានកំរិតទាបសំរាប់កម្មករនិយោជិតជាច្រើន ដើម្បីអាចបំពេញតំរូវការជាមូលដ្ឋានរបស់ពួកគេបាន ហើយខណៈពេលដែលកម្មករនិយោជិតមួយចំនួន អាចមើលឃើញពីការធ្លាក់ចុះបរិមាណពេលវេលាដែលពួកគេប្ដូរជាចំពោះការងារ ភាពមិនអាចព្យាករណ៍ទុកជាមុនបានដែលមានអមមកជាមួយ អាចធ្វើអន់ថយដល់ភាពមានការងារធ្វើជាប់លាប់ និងបង្កើតអោយមានជាការលំបាកថ្មីៗ ចំពោះការសំរបសំរួលរវាងការងារ និងគ្រួសារ។ លក្ខខណ្ឌការងារអាក្រក់ និងគ្រោះថ្នាក់ដែលកំពុងធ្លាក់ចុះនៅក្នុងប្រទេសឧស្សាហកម្ម កំពុងបន្តមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងពេលជាមួយគ្នានេះ ភាពតានតឹងអារម្មណ៍ និងអំពើហិង្សាដែលពាក់ព័ន្ធនឹងការងារកំពុងចាប់ផ្ដើមមានការទទួលស្គាល់ជាសកល ថាជាបញ្ហាចំបង។

ប្រាក់ឈ្នួល ម៉ោងធ្វើការ ការរៀបចំការងារ លក្ខខណ្ឌការងារ និងការសំរបជីវិតការងារទៅនឹងតំរូវការរបស់ជីវិតនៅក្រៅការងារ គឺជាធាតុសំខាន់ៗនៃទំនាក់ទំនងការងារ និងនៃកិច្ចការពារកម្មករនិយោជិត ក៏ដូចជាទិដ្ឋភាពសំខាន់ៗនៃដំណើរការសេដ្ឋកិច្ច ដូច្នេះហើយបានជាវាក្លាយជាចំណាប់អារម្មណ៍សំខាន់របស់អង្គការពលកម្មអន្តរជាតិ។ បញ្ហាទាំងនេះ គឺផ្នែកសំខាន់ៗនៃការគ្រប់គ្រងធនធានមនុស្ស ការចរចាជាសមូហភាព និងកិច្ចសន្ទនាសង្គម ក៏ដូចជាគោលនយោបាយរបស់រដ្ឋាភិបាល។





# ការការពារខាងសង្គមកិច្ច

បុរស និងស្ត្រីភាគច្រើន មិនមានការការពារខាងសង្គមកិច្ចក្នុងក៏រិតមួយគ្រប់គ្រាន់នោះទេ។ ពួកគេប្រឈមនឹងគ្រោះថ្នាក់នៅកន្លែងការងារ និងកង្វះការផ្តល់សោធននិវត្តន៍ និងការធានារ៉ាប់រងសុខភាពតិចតួច ឬគ្មានសោះ។ មនុស្សមួយចំនួន មិនត្រូវបានអនុញ្ញាតអោយមានការសំរាកគ្រប់គ្រាន់ ហើយស្ត្រីជាច្រើនខាតអត្ថប្រយោជន៍មាតុភាព។ បទដ្ឋានការងារអន្តរជាតិ និងអង្គការសហប្រជាជាតិ ទទួលស្គាល់ថាការការពារខាងសង្គមកិច្ច គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន។ លើសពីនេះទៅទៀត ប្រព័ន្ធការពារខាងសង្គមកិច្ចដែលមានការរៀបចំបានល្អធ្វើអោយសេដ្ឋកិច្ចមានការរីកចំរើន ដែលចូលរួមចំណែកបង្កើនភាពប្រកួតប្រជែង។ អង្គការពលកម្មអន្តរជាតិប្តេជ្ញាចិត្តជួយដល់ប្រទេសនានា ក្នុងការពង្រីកការការពារខាងសង្គមកិច្ចអោយដល់មនុស្សគ្រប់ក្រុមទាំងអស់នៅក្នុងសង្គម និងកែលំអលក្ខខ័ណ្ឌការងារ និងសុវត្ថិភាពនៅកន្លែងការងារ។



អង្គការពលកម្មអន្តរជាតិប្តេជ្ញាចិត្ត**ជួយ**ដល់ប្រទេសនានា ក្នុងការ**ពង្រីកការការពារខាងសង្គមកិច្ច**អោយដល់មនុស្សគ្រប់ក្រុមទាំងអស់នៅក្នុងសង្គម

# សន្តិសុខសង្គម

មានប្រជាពលរដ្ឋនៅក្នុងពិភពលោកតែ ២០ ភាគរយតែប៉ុណ្ណោះ ដែលទទួលបានសេវាសន្តិសុខសង្គមគ្រប់គ្រាន់ ហើយជាងពាក់កណ្តាលខ្វះខាតសេវានេះទាំងស្រុង។ ស្ថានភាពនេះ ឆ្លុះបញ្ចាំងពីកំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយកម្មករនិយោជិតតិចជាង ១០ ភាគរយ នៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ទទួលបានសេវាសន្តិសុខសង្គម។ នៅក្នុងប្រទេសដែលមានចំណូលធុនកណ្តាល សេវានេះគ្របដណ្តប់ពី ២០ ទៅ ៦០ ភាគរយ ខណៈដែលនៅក្នុងប្រទេសឧស្សាហកម្មភាគច្រើន សេវានេះមានស្ទើរតែ ១០០ ភាគរយ។

សន្តិសុខសង្គម រួមមាន ការទទួលបានការថែទាំសុខភាព និងសន្តិសុខចំណូល ជាពិសេសនៅក្នុងករណីជរា គ្មានការងារធ្វើ ឈឺ ទុពលភាព គ្រោះថ្នាក់ការងារ មាតុភាព ឬការបាត់បង់អ្នករកចំណូលសំខាន់។

កង្វល់នៅក្នុងចំណោមរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត បានធ្វើអោយអង្គការពលកម្មអន្តរជាតិបង្កើតនូវ "យុទ្ធនាការជាសកលស្តីពីសន្តិសុខសង្គម និងសេវាគ្របដណ្តប់សំរាប់មនុស្សគ្រប់គ្នា" នៅក្នុងឆ្នាំ ២០០៣។ យុទ្ធនាការនេះ ប្រើប្រាស់កិច្ចខំប្រឹងប្រែងរបស់អង្គការពលកម្មអន្តរជាតិ ដែលកំពុងមានស្រាប់នៅក្នុងប្រទេសជាង ៣០។ កិច្ចខំប្រឹងប្រែងទាំងនេះ រួមមានគំរោងជួយប្រទេសនានា អោយពង្រីកការគ្របដណ្តប់នៅកំរិតជាតិ និងពង្រឹងអង្គការសន្តិសុខសង្គមនៅតាមសហគមន៍។ អង្គការពលកម្មអន្តរជាតិក៏កំពុងធ្វើការស្រាវជ្រាវយ៉ាងសំខាន់ដើម្បីកំណត់ពីកត្តានានា ដែលធ្វើអោយអន្តរាយដល់សន្តិសុខរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។



# ចំណាកស្រុកអន្តរជាតិ



ជិតពាក់កណ្តាលនៃជនចំណាកស្រុក និងជនភៀសខ្លួននៅទូទាំងពិភពលោក (ឬមនុស្សពេញវ័យប្រមាណ ៨៦ លាននាក់) មានការចូលរួមផ្នែកសេដ្ឋកិច្ចយ៉ាងសកម្ម ត្រូវបានជួលអោយធ្វើការងារ ឬពាក់ព័ន្ធនឹងសកម្មភាពទទួលបានប្រាក់កំរៃ។ ចំនួនជនចំណាកស្រុកដែលឆ្លងព្រំដែនដើម្បីស្វែងរកការងារធ្វើ និងសន្តិសុខ ត្រូវបានគេរំពឹងថានឹងកើនឡើងយ៉ាងលឿននៅក្នុងទសវត្សរ៍ខាងមុខនេះ ដោយសារតែបរាជ័យរបស់សកលភាវូបនីយកម្មក្នុងការបង្កើតការងារ និងឱកាសសេដ្ឋកិច្ច។ ការត្រួតពិនិត្យផ្នែកអន្តោប្រវេសន៍យ៉ាងតឹងរ៉ឹង និងរបាំងឧបសគ្គដែលដាក់ដោយប្រទេសទទួលយកជនអន្តោប្រវេសន៍ធំៗជាច្រើន បានបង្កើតអោយមានបញ្ហាកង្វល់ជាច្រើនដូចជា ឧបទ្ទវហេតុនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចក្នុងកំរិតខ្ពស់លើកម្មករនិយោជិតដែលជាជនចំណាកស្រុកនៅក្នុងសង្គមដែលទទួលពួកគេ។

អង្គការពលកម្មអន្តរជាតិ មើលឃើញបញ្ហាប្រឈមជាសកលនាពេលបច្ចុប្បន្ននេះថា ជាការបង្កើតអោយចេញគោលនយោបាយ និងធនធាននានា ដើម្បីគ្រប់គ្រងពលកម្មចំណាកស្រុកអោយបានកាន់តែល្អប្រសើរ ដើម្បីអោយវាអាចរួមចំណែកជាវិជ្ជមានចំពោះការរីកចំរើន និងការអភិវឌ្ឍន៍របស់ប្រទេសដែលជាដើមកំណើតផង និងរបស់ប្រទេសដែលទទួលពួកគេផង ក៏ដូចជាចំពោះសុខមាលភាពរបស់ជនចំណាកស្រុកខ្លួនឯង។

# សុខភាព និងសុវត្ថិភាព

អង្គការពលកម្មអន្តរជាតិ ផ្តល់សារៈសំខាន់ជាពិសេស ដល់ការបង្កើត និងការអនុវត្តន៍**វប្បធម៌សុវត្ថិភាព និងសុខភាព តាមបែបបង្ការ**នៅកន្លែងការងារ**នៅទូទាំងពិភពលោក**



ជារៀងរាល់ឆ្នាំ ប្រជាជនជាង ២ លាននាក់ ស្លាប់ដោយសារគ្រោះថ្នាក់ការងារ ឬជំងឺដែលទាក់ទងនឹងការងារ ។ បើតាមការប៉ាន់ស្មានដែលមានលក្ខណៈអភិរក្សនិយម មានគ្រោះថ្នាក់ការងារចំនួន ២៧០ លានករណី និងជំងឺវិជ្ជាជីវៈចំនួន ១៦០ លានករណី ។

សុវត្ថិភាពការងារមានការខុសប្លែកគ្នាយ៉ាងសំបើម រវាងប្រទេស រវាងវិស័យសេដ្ឋកិច្ច និងរវាងក្រុមសង្គមផ្សេងៗ ។ ការស្លាប់ និងការរងរបួសមានចំនួនខ្ពស់ ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រជាជនជាច្រើននាក់កំពុងពាក់ព័ន្ធនឹងសកម្មភាពគ្រោះថ្នាក់ ដូចជា កសិកម្ម សំណង់ ការកាប់ព្រៃឈើ ការនេសាទ និងការជីករ៉ែ ។ នៅទូទាំងពិភពលោក ប្រជាជនក្រីក្រ និងដែលមានការការពារតិចជាងគេ ដែលជានិច្ចកាលជាស្ត្រី កុមារ និងជនចំណាកស្រុក គឺស្ថិតនៅក្នុងចំណោមអ្នកដែលរងផលប៉ះពាល់ច្រើនជាងគេ ។

ដោយសារតែវឌ្ឍនភាព ដែលប្រទេសឧស្សាហកម្មជាច្រើនបានបង្កើតឡើងក្នុងការកាត់បន្ថយគ្រោះថ្នាក់ធ្ងន់ៗ វាបង្ហាញចេញយ៉ាងច្បាស់ថា ការកែលំអសុវត្ថិភាពនៅកន្លែងការងារពិតជាមានលទ្ធផលមែន ។ យ៉ាងណាក៏ដោយ នៅមានកង្វះខាតផ្នែកការយល់ដឹងចំណេះដឹង និងព័ត៌មានអំពីបញ្ហានេះ ។ អង្គការពលកម្មអន្តរជាតិធ្វើការងារ ដើម្បីបំពេញគំលាតនេះ តាមរយៈការស្រាវជ្រាវ ការតស៊ូមតិ និងជំនួយបច្ចេកទេស ។ អង្គការនេះជួយប្រទេសនានាក្នុងការបង្កើតឧបករណ៍គ្រប់គ្រង សេវាពិនិត្យតាមដាន និងសេវាព័ត៌មាន ដោយផ្តោតជាចំបងទៅលើការងារដែលមានគ្រោះថ្នាក់ ។

អង្គការពលកម្មអន្តរជាតិ ផ្តល់សារៈសំខាន់ជាពិសេសដល់ការបង្កើត និងការអនុវត្តន៍វប្បធម៌សុវត្ថិភាព និងសុខភាព តាមបែបបង្ការនៅកន្លែងការងារនៅទូទាំងពិភពលោក ។

# មេរោគអេដស៍/ជំងឺអេដស៍



ក្នុងរយៈពេលយ៉ាងខ្លី ការរាតត្បាតនៃមេរោគអេដស៍/ជំងឺអេដស៍ បានក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗជាងគេនៅកន្លែងការងារនៅក្នុងសម័យកាលរបស់យើង។ ប្រជាជននៅវ័យធ្វើការងារចំនួនជិត ៤០ លាននាក់ មានផ្ទុកមេរោគអេដស៍ ហើយកំលាំងពលកម្មសកលលោកបានបាត់បង់កម្មករនិយោជិតប្រមាណ ២៨ លាននាក់ ដោយសារជំងឺអេដស៍ចាប់តាំងពីមានការឆ្លងរាលដាលជំងឺនេះ កាលពី ២០ ឆ្នាំមុនមក។

បន្ថែមលើផលប៉ះពាល់យ៉ាងហិនហោចនៃការឆ្លងរាលដាលមកលើស្ត្រី និងបុរស ព្រមទាំងគ្រួសាររបស់ពួកគេទាំងនេះ វាធ្វើអោយប៉ះពាល់ដល់ពិភពការងារតាមវិធីជាច្រើន។ ឧទាហរណ៍ ការរើសអើងប្រឆាំងនឹងមនុស្សដែលមានមេរោគអេដស៍/ជំងឺអេដស៍ គំរាមកំហែងដល់សិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ ធ្វើអោយខូចឱកាសសំរាប់មនុស្សក្នុងការទទួលបាននូវការងារសមរម្យ។

បន្ទាប់ពីការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត នៅក្នុងឆ្នាំ ២០០១ អង្គការពលកម្មអន្តរជាតិ បានអនុម័តលើក្រមប្រតិបត្តិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ និងពិភពការងារ។

ក្រមប្រតិបត្តិនាំមុខគេនេះ ត្រូវបានបង្កើតឡើង ដើម្បីជួយបង្ការការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ហើយក្នុងពេលជាមួយគ្នានេះអាចគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់របស់វានៅកន្លែងការងារបាន។ ក្នុងចំណោមគោលការណ៍សំខាន់ៗរបស់ក្រមប្រតិបត្តិនេះ មានដូចជា ការមិនរើសអើង សមភាពយេនឌ័រ បរិស្ថានការងារប្រកបដោយសុខភាពល្អ ការពុំធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងគោលបំណងចូលធ្វើការងារ ការរក្សាការសំងាត់ និងការបន្តទំនាក់ទំនងការងារ។ ក្រមប្រតិបត្តិនេះកំពុងដើរតួជាចំនុចយោងកាន់តែច្រើនឡើង សំរាប់អោយនិយោជក និងសហជីព ធ្វើការចរចាលើកិច្ចព្រមព្រៀង ស្តីពីការដោះស្រាយបញ្ហាមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងពិភពការងារ។























ការិយាល័យអង្គការពលកម្មអន្តរជាតិ
ផ្នែកព័ត៌មាន និងទំនាក់ទំនងសាធារណៈ
អាគារលេខ ៤ ផ្លូវ Morillons
CH-១២១១ ហ្សឺណែវ ២២ ប្រទេសស្វីស
ទូរស័ព្ទ : +៤១ ២២ ៧៧៩ ៧៩១២
ទូរសារ : +៤១ ២២ ៧៩៩ ៨៥៧៧
អ៊ីម៉ែល : communication@ilo.org
www.ilo.org

មជ្ឈមណ្ឌលភ្នំពេញ
អាគារ F ជាន់ទី ២
មហាវិថីសីហនុ និងសុធារស
ប្រអប់សំបុត្រលេខ ២៦៤២
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : +៨៥៥ ២៣ ២២០ ៨១៧
ទូរសារ : +៨៥៥ ២៣ ២២១ ៥៣៦
អ៊ីម៉ែល : ilopnh@ilo.org









978-92-2-820580-0
12/2007


Photos © ILO . Design www.paprika-annecy.com